**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សូមគោរពជូន**

**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

នៅក្នុងឱកាសដ៏ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លាដែល **សម្តេចតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានក្រុមប្រឹក្សាទេសចរណ៍ និងពាណិជ្ជកម្មអឺរ៉ុបជ្រើសតាំងជា « ឯកអគ្គរដ្ឋទូតសុច្ឆន្ទៈពិភពលោក សម្រាប់វិស័យទេសចរណ៍ និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព» និងការប្រគល់ពានរង្វាន់ដល់រាជធានីភ្នំពេញ ជារាជធានីនៃទេសចរណ៍ និងវប្បធម៌ ពិភពលោក សម្រាប់ឆ្នាំ ២០១៧-២០១៨ ។

តាងនាមថ្នាក់ដឹកនាំ ក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមសម្តែងនូវមនោសញ្ចេតនាសោមនស្សរីករាយឥតឧបមានិងអបអរសាទរយ៉ាងក្លៀវក្លាបំផុតចំពោះ **សម្តេចតេជោ** ដែលទទួលបាននូវកិត្តិយសដ៏ឧត្តុង្គឧត្តម ជាការឆ្លើយតបយ៉ាងស័ក្តិសមបំផុតចំពោះស្នាដៃដឹកនាំរបស់ **សម្តេច** ដែលបានថែរក្សា សុខសន្តិភាព នាំមកនូវជោគជ័យដ៏ត្រចះត្រចង់ ទាំងលើផ្នែកនយោបាយ សន្តិសុខសង្គម ទេសចរណ៍ និងការអភិវឌ្ឍន៍ ទទួលបាននូវការគាំទ្រ និងការជឿជាក់ពីគ្រប់មជ្ឈដ្ឋាននៅក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ។

ការជ្រើសតាំង **សម្តេចតេជោ** ជា «ឯកអគ្គរដ្ឋទូតសុច្ឆន្ទៈពិភពលោក» នេះ គឺជាកិត្តិយស ដ៏ឧត្តុង្គឧត្តម សម្រាប់ **សម្តេច** និងក្រុមគ្រួសាររបស់ **សម្តេច** ក៏ដូចជាសម្រាប់ប្រទេសជាតិនិងប្រជាជនកម្ពុជាទាំងមូល និងជាការឆ្លើយតបយ៉ាងស័ក្តិសមបំផុតចំពោះស្នាដៃដឹកនាំរបស់ **សម្តេច** ដែលបាន ជំរុញឲ្យមានការអភិវឌ្ឍរីកចម្រើនយ៉ាងខ្លាំងលើវិស័យទេសចរណ៍ ទទួលបានកំណើនភ្ញៀវទេសចរកើនឡើងជាលំដាប់ ជាមួយនឹងការការពារសន្តិសុខ សុវត្ថិភាពជូនភ្ញៀវបានយ៉ាងល្អប្រសើរ។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការគោរពជូនពរ ចំពោះ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីទាំងអស់ សូមមានសុខភាពល្អ បរិបូរណ៍ ជន្មាយុយឺនយូរ បញ្ញាញាណភ្លឺថ្លា ដើម្បីបន្តដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយវឌ្ឍនភាព និងវិបុលភាពតរៀងទៅ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

ថ្ងៃ សៅរ៍ ៦រោច ខែ មិគសិរ ឆ្នាំរកា ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៩ ខែធ្នូ គ.ស២០១៧
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**